ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
លេខៈ ០០១ សរ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ ០០៤...សរ

# សារាចរអន្តរក្រសួង
# ស្តីពី
# វិធានការការពារជាបណ្តោះអាសន្ន នូវដីដែលសហគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជីដី ក្នុងពេលរង់ចាំការចុះបញ្ជីដីនោះ ជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ត្រូវបានបញ្ចប់តាមនីតិវិធី

តាមច្បាប់ភូមិបាលឆ្នាំ២០០១ ជនជាតិដើមភាគតិចដែលបានរស់នៅប្រមូលផ្តុំ និងគ្រប់គ្រង ប្រើប្រាស់ដីធ្លីជាលក្ខណៈសមូហភាពតាមប្រពៃណី និងទំនៀមទម្លាប់នៃជនជាតិរបស់ខ្លួន នឹងទទួលបានសិទ្ធិកម្មសិទ្ធិលើក្បាលដីដែលសហគមន៍ជនជាតិដើមភាគតិចនីមួយៗបាន និងកំពុងកាន់កាប់ និងប្រើប្រាស់ជាក់ស្តែងនោះ ជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍។ ក្នុងស្មារតីនេះ ដោយការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចជាកិច្ចការថ្មី រាជរដ្ឋាភិបាលបានអនុវត្តគម្រោងកម្មវិធីសាកល្បងអំពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាពចំនួនបីសហគមន៍ ក្នុងនោះមាន ០២សហគមន៍ នៅខេត្តរតនគិរី និង ០១សហគមន៍ នៅខេត្តមណ្ឌលគិរី។ លើមូលដ្ឋាននេះ គោលនយោបាយស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ក៏បានដាក់ចេញជាបន្តបន្ទាប់។

ដើម្បីប្រសិទ្ធភាពអនុវត្តន៍នូវគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តខាងលើនៅក្នុងក្របខណ្ឌទូទាំងប្រទេស ក្រោយពីគម្រោងសាកល្បងស្តីពីការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានបញ្ចប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ លើជ្រុងនៃកំណែទម្រង់ដីធ្លី បានកំណត់ឱ្យមានការដាក់ចេញនូវវិធានការការពារបណ្តោះអាសន្ន ចំពោះក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងឡាយដែលបានបង្កើត និងមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ រហូតដល់ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ត្រូវបានចប់សព្វគ្រប់តាមនីតិវិធី។ លើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មនេះ និងលិខិតលេខ ៥២៥ សជណ.ឧស សជណ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំគោលការណ៍ដាក់ចេញនូវវិធានការបណ្តោះអាសន្ន នូវដីរបស់សហគមន៍ជនជាតិដើមភាគតិចដែលជាតំបន់គោលដៅសម្រាប់ការចុះបញ្ជីដីធ្លីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ រួមទាំងរបាយការណ៍វាយតម្លៃ

លទ្ធផល នៃការអនុវត្តគម្រោងសិក្សាសាកល្បងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច របស់ខេត្តទាំងពីរ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** សម្រេចដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំការអនុវត្ត ដូចតទៅ ៖

នៅពេលបានទទួលពាក្យស្នើសុំចុះបញ្ជីដីរបស់សហគមន៍ជាកម្មសិទ្ធិសមូហភាព ពីសហគមន៍ជនជាតិដើមភាគតិចណាមួយ អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត នៃខេត្តដែលសហគមន៍ជនជាតិដើមភាគតិចជាសាមីសំណើនោះរស់នៅ **ត្រូវរៀបចំសេចក្តីព្រាងដីកាដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តជាបន្ទាន់** ដើម្បីអនុវត្តនូវវិធានការការពារដីដែលស្ថិតក្នុងតំបន់ដីរបស់សហគមន៍ស្នើសុំចុះបញ្ជីដីនោះ ដោយណែនាំដល់ :

១-ប្រជាពលរដ្ឋ ឱ្យផ្អាកជាបណ្តោះអាសន្ននូវការទិញ ការលក់ ការជួល ឬការផ្ទេរតាមគ្រប់រូបភាព។

២-អាជ្ញាធរក្រោមឱវាទនៃដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យផ្អាកនូវការបញ្ជាក់លើលិខិតយថាភូតនានា ទាក់ទងនឹងករណីនៃចរន្តការដី នូវរាល់ក្បាលដីដែលសហគមន៍ស្នើសុំចុះបញ្ជី និងក្បាលដីផ្សេងទៀតដែលមានព្រំប្រទល់ជាប់ក្បាលដីដែលសហគមន៍ស្នើសុំចុះបញ្ជី រហូតដល់ក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះត្រូវបានចុះបញ្ជីដីធ្លីចប់សព្វគ្រប់តាមនីតិវិធី ។

ប៉ុន្តែការទប់ស្កាត់ជាបណ្តោះអាសន្នទាំងពីរករណីដូចបានលើកឡើងខាងលើ ត្រូវបានលើកលែងចំពោះក្បាលដីទាំងឡាយដែលនៅមុនពេលនៃការដាក់ចេញនូវវិធានការនេះ ជាក្បាលដីមានការកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានការឯកភាពពីគ្រប់អ្នកពាក់ព័ន្ធរួចហើយ ក៏ដូចជាដីរបស់រដ្ឋដែលរាជរដ្ឋាភិបាលមានគោលការណ៍ឱ្យវិនិយោគ ឬអភិវឌ្ឍន៍ ដើម្បីចៀសវាងផលប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិឯកជន និងសាធារណៈ លើដីដែលបានកាន់កាប់ និងមានគោលការណ៍ច្បាស់លាស់ត្រឹមត្រូវតាមច្បាប់ជាធរមានរួចហើយ។

ដីកានៃការទប់ស្កាត់ជាបណ្តោះអាសន្នរបស់ខេត្ត ត្រូវថតចម្លង និងផ្សព្វផ្សាយជាសាធារណៈដល់គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជូនជ្រាប និងសុំកិច្ចសហការអនុវត្ត។

ទទួលបានសារាចរណែនាំនេះ ក្រុមប្រឹក្សា អភិបាល នៃគណៈអភិបាលខេត្ត ក្រុង ស្រុក មេឃុំ ចៅសង្កាត់ គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច ប្រជាពលរដ្ឋ គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធត្រូវអនុវត្ត និងផ្តល់កិច្ចសហការអនុវត្តសារាចរនេះ ឱ្យបានរលូន និងមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី..៣១.. ខែ ឧសភា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី**
**នគរូបនីយកម្ម និងសំណង់**

អ៊ឹម ឈុនលឹម